នស/រកត/០៥២៦/៥៩៤

# ព្រះរាជក្រឹត្យ
# ស្តីពី
# លក្ខន្តិកៈនៃអគ្គសុខាភិបាល
# យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១១៦០/១៤ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- បានទទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានទទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

# ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ព្រះរាជក្រឹត្យនេះ កំណត់អំពីលក្ខន្តិកៈនៃអង្គសុខាភិបាល ដើម្បីប្រមូលផ្តុំនិងគ្រប់គ្រងមន្ត្រីសុខាភិបាលដែលជាអ្នកវិជ្ជាជីវៈបានទទួលការអប់រំ ការបណ្តុះបណ្តាល បទពិសោធការងារ ចំណេះដឹង និងបំពេញការងារក្នុងវិស័យសុខាភិបាល។

**មាត្រា២ .-**

ព្រះរាជក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីសុខាភិបាល ដែលបម្រើការងារក្នុងវិស័យសុខាភិបាលនៅតាមអង្គភាពនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី២

## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៣ .-**

ក្រសួងសុខាភិបាល មានសមត្ថកិច្ចគ្រប់គ្រងអង្គសុខាភិបាល ដើម្បីធានានូវសង្គតិភាពនិងគុណភាពនៃមន្ត្រីសុខាភិបាល។

ក្រសួងសុខាភិបាល មានសមត្ថកិច្ចពិនិត្យនិងធានានូវនីត្យានុកូលភាព និងត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- ណែនាំដល់អង្គភាពក្រោមឱវាទផ្ទាល់របស់ក្រសួងនិងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិតឱ្យអនុវត្តមុខងារនិងភារកិច្ចដោយអនុលោមតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងនិងចាត់ចែងមន្ត្រីសុខាភិបាល ដែលត្រូវបានផ្ទេរឬដាក់ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពនិងរដ្ឋបាលថ្នាក់ក្រោមជាតិសាមី
- បង្គាប់ដល់អង្គភាពក្រោមឱវាទផ្ទាល់របស់ក្រសួងនិងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិតឱ្យកែប្រែឬលុបសេចក្តីសម្រេចរបស់ខ្លួនដែលផ្ទុយនឹងបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ
- ចេញសេចក្តីសម្រេចព្យួរឬលុបសេចក្តីសម្រេចរបស់អង្គភាពក្រោមឱវាទផ្ទាល់របស់ក្រសួង ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ
- ស្នើក្រសួងមហាផ្ទៃចាត់វិធានការកែតម្រូវ ឬព្យួរ ឬក៏លុបសេចក្តីសម្រេចឬដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលផ្ទុយនឹងបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ
- លើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីមានវិធានការធានានីត្យានុកូលភាព ក្នុងករណីដែលសេចក្តីសម្រេចរបស់ក្រសួង ស្ថាប័ននានា ផ្ទុយនឹងបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

**មាត្រា៤ .-**

ក្រសួងសុខាភិបាលនិងក្រសួងមុខងារសាធារណៈ ត្រូវសហការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលតម្រូវដោយព្រះរាជក្រឹត្យនេះ ព្រមទាំងកំណត់សេចក្តីណែនាំ បែបបទនិងនីតិវិធីចាំបាច់ដើម្បីធានាការអនុវត្តព្រះរាជក្រឹត្យឱ្យមានប្រសិទ្ធភាព។

## ជំពូកទី៣
## មុខតំណែងក្នុងអង្គសុខាភិបាល

**មាត្រា៥ .-**

មុខតំណែងក្នុងអង្គសុខាភិបាលមាន មុខតំណែងវិជ្ជាជីវៈនិងមុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង។

មុខតំណែងវិជ្ជាជីវៈនិងមុខតំណែងគ្រប់គ្រង ត្រូវមានការពិពណ៌នាអំពីមុខតំណែងនិងការបញ្ជាក់អំពីគុណវុឌ្ឍិនៃមុខតំណែងនីមួយៗ ឱ្យបានច្បាស់លាស់។

មុខតំណែងក្នុងអង្គសុខាភិបាល ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

មុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ជំពូកទី៤
## ការជ្រើសរើស

**មាត្រា៦ .-**

ការជ្រើសរើសមន្ត្រីសុខាភិបាលចូលក្នុងអង្គសុខាភិបាល ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងពីក្នុងចំណោមបេក្ខជនដែលមានគុណវុឌ្ឍិសមស្របទៅនឹងមុខតំណែងដែលត្រូវជ្រើសរើស។

ចំនួនមុខតំណែងដែលជ្រើសរើស ត្រូវអនុវត្តផ្អែកលើផែនការនិងគម្រោងថវិកាប្រចាំឆ្នាំនីមួយៗ ដែលសម្រេចដោយរាជរដ្ឋាភិបាល។

**មាត្រា៧ .-**

បែបបទ នីតិវិធី និងយន្តការនៃការប្រឡងប្រជែងជ្រើសរើសមន្ត្រីសុខាភិបាល ត្រូវអនុវត្តដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៨ .-**

បេក្ខជនដែលអាចចូលរួមប្រឡងប្រជែងជ្រើសរើសជាមន្ត្រីសុខាភិបាល ត្រូវបំពេញលក្ខណវិនិច្ឆ័យមូលដ្ឋានដូចខាងក្រោម៖

- សញ្ជាតិខ្មែរ
- លក្ខខណ្ឌអាយុ ផ្អែកលើការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សញ្ញាបត្រជំនាញវិជ្ជាជីវៈសុខាភិបាល ស្របតាមការតម្រូវនៃមុខតំណែង
- មិនបានប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
- មិនដែលមានទោសឧក្រិដ្ឋឬមជ្ឈិមពីរឿងល្មើសប៉ះពាល់ដល់ទំនៀមទម្លាប់ កិត្តិយស និងភាពសុចរិត។

លក្ខណវិនិច្ឆ័យលម្អិតនិងគុណវុឌ្ឍិផ្សេងទៀតសម្រាប់មុខតំណែងនីមួយៗ ត្រូវកំណត់ដោយក្រសួងសុខាភិបាលនិង/ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ជំពូកទី៥
## មន្ត្រីសុខាភិបាលក្នុងក្របខ័ណ្ឌមន្ត្រីរាជការ
## ផ្នែកទី១
## ក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់

**មាត្រា៩ .-**

មន្ត្រីសុខាភិបាលក្នុងក្របខ័ណ្ឌមន្ត្រីរាជការនៃអង្គសុខាភិបាល ត្រូវបានរៀបចំឱ្យស្ថិតក្នុងក្របខ័ណ្ឌចំនួន៣(បី) ដូចខាងក្រោម៖

១- ក្របខ័ណ្ឌមន្ត្រីសុខាភិបាលឧត្តម ជាក្របខ័ណ្ឌប្រភេទ ក។
២- ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ជាក្របខ័ណ្ឌប្រភេទ ខ។
៣- ក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ជាក្របខ័ណ្ឌប្រភេទ គ។

**មាត្រា១០ .-**

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលឧត្តម ប្រមូលផ្តុំអ្នកវិជ្ជាជីវៈសុខាភិបាល ដែលមានសញ្ញាបត្រជំនាញវិជ្ជាជីវៈសុខាភិបាលកម្រិតបរិញ្ញាបត្រឬសមមូលឡើងទៅ និងទទួលស្គាល់ដោយគណៈវិជ្ជាជីវៈសុខាភិបាល ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មន្ត្រីសុខាភិបាលឧត្តម មានមុខងារគ្រប់គ្រង ដឹកនាំ សិក្សាស្រាវជ្រាវ ផ្តល់យោបល់ រៀបចំផែនការគោលនយោបាយ និងប្រតិបត្តិលើផ្នែកវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តវេទនសាស្ត្រ សុខភាពសាធារណៈ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ។

**មាត្រា១១ .-**

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលឧត្តម មាន៣(បី)ឋានន្តរសក្តិ ដូចខាងក្រោម៖

- ឋានន្តរសក្តិទី១ ជាឋានន្តរសក្តិមន្ត្រីសុខាភិបាលឧត្តមដើមខ្សែពិសេស មាន៦(ប្រាំមួយ)ថ្នាក់
- ឋានន្តរសក្តិទី២ ជាឋានន្តរសក្តិមន្ត្រីសុខាភិបាលឧត្តមដើមខ្សែ មាន៤(បួន)ថ្នាក់
- ឋានន្តរសក្តិទី៣ ជាឋានន្តរសក្តិមន្ត្រីសុខាភិបាលឧត្តម មាន៤(បួន)ថ្នាក់។

**មាត្រា១២ .-**

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ប្រមូលផ្តុំអ្នកវិជ្ជាជីវៈសុខាភិបាល ដែលមានសញ្ញាបត្រជំនាញវិជ្ជាជីវៈសុខាភិបាលកម្រិតបរិញ្ញាបត្ររងឬសមមូលឡើងទៅ និងទទួលស្គាល់ដោយគណៈវិជ្ជាជីវៈសុខាភិបាល ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មន្ត្រីសុខាភិបាលមធ្យម មានមុខងារជានានូវប្រតិបត្តិការ គ្រប់គ្រង ដឹកនាំ សិក្សាស្រាវជ្រាវ ជួយដល់មន្ត្រីសុខាភិបាលឧត្តមលើការអនុវត្តមុខងារ ដូចមានកំណត់ក្នុងមាត្រា១០ នៃព្រះរាជក្រឹត្យនេះ។

**មាត្រា១៣ .-**

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម មាន៣(បី)ឋានន្តរសក្តិ ដូចខាងក្រោម៖

- ឋានន្តរសក្តិទី១ ជាឋានន្តរសក្តិមន្ត្រីសុខាភិបាលមធ្យមដើមខ្សែពិសេស មាន៦(ប្រាំមួយ)ថ្នាក់
- ឋានន្តរសក្តិទី២ ជាឋានន្តរសក្តិមន្ត្រីសុខាភិបាលមធ្យមដើមខ្សែ មាន៤(បួន)ថ្នាក់
- ឋានន្តរសក្តិទី៣ ជាឋានន្តរសក្តិមន្ត្រីសុខាភិបាលមធ្យម មាន៤(បួន)ថ្នាក់។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា១៤ .-**

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ប្រមូលផ្តុំអ្នកវិជ្ជាជីវៈសុខាភិបាល ដែលមានសញ្ញាបត្រជំនាញវិជ្ជាជីវៈសុខាភិបាលកម្រិតបឋមឬសមមូលឡើងទៅ និងទទួលស្គាល់ដោយគណៈវិជ្ជាជីវៈសុខាភិបាល ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មន្ត្រីសុខាភិបាលបឋម បំពេញមុខងារប្រតិបត្តិការ ដើម្បីចូលរួម និងគាំទ្រជាជំនួយដល់ការអនុវត្តមុខងារផ្នែកវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តវទនសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ។

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម មាន១០(ដប់)ថ្នាក់ និងពុំមានបែងចែកជាឋានន្តរសក្តិទេ។

## ផ្នែកទី២
## ការបណ្តុះបណ្តាលតម្រង់ទិស កម្មសិក្សា និងការតាំងស៊ប់

**មាត្រា១៥ .-**

បេក្ខជនដែលប្រឡងជាប់ជាមន្ត្រីសុខាភិបាល ត្រូវទទួលការបណ្តុះបណ្តាលតម្រង់ទិស តាមការកំណត់របស់ក្រសួងសុខាភិបាល មុននឹងត្រូវចាត់តាំងឱ្យធ្វើកម្មសិក្សា។

**មាត្រា១៦ .-**

ក្រោយបញ្ចប់ការបណ្តុះបណ្តាលតម្រង់ទិស មន្ត្រីសុខាភិបាលនឹងត្រូវបានចាត់តាំងឱ្យទៅធ្វើកម្មសិក្សានៅតាមបណ្តាអង្គភាពនៃក្រសួង ស្ថាប័នសាមី និងទីតាំងភូមិសាស្ត្រដែលបានប្រឡងជាប់។

**មាត្រា១៧ .-**

រយៈពេលនៃការបណ្តុះបណ្តាលក្នុងវិជ្ជាជីវៈសុខាភិបាល ត្រូវចាត់ទុកជាផ្នែកមួយនៃការធ្វើកម្មសិក្សា។ រយៈពេលនៃកម្មសិក្សារបស់មន្ត្រីសុខាភិបាល ត្រូវបានកំណត់ដូចខាងក្រោម៖

១- មន្ត្រីសុខាភិបាលឧត្តម ត្រូវធ្វើកម្មសិក្សារយៈពេល១២(ដប់ពីរ)ខែ។
២- មន្ត្រីសុខាភិបាលមធ្យម ត្រូវធ្វើកម្មសិក្សារយៈពេល១២(ដប់ពីរ)ខែ។
៣- មន្ត្រីសុខាភិបាលបឋម ត្រូវធ្វើកម្មសិក្សារយៈពេល១២(ដប់ពីរ)ខែ។
៤- មន្ត្រីសុខាភិបាលដែលត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការ ដែលស្ថិតក្នុងអង្គសុខាភិបាល មិនតម្រូវឱ្យធ្វើកម្មសិក្សាឡើយ។

**មាត្រា១៨ .-**

មន្ត្រីសុខាភិបាល ដែលត្រូវចាត់តាំងឱ្យធ្វើកម្មសិក្សា ត្រូវទទួលបៀវត្សតាមឋានន្តរសក្តិ និងថ្នាក់ដំបូងនៃក្របខ័ណ្ឌនីមួយៗ ឬទទួលបានសន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់នៃសន្ទស្សន៍ចាស់របស់សាមីខ្លួន ចំពោះមន្ត្រីសុខាភិបាលដែលជ្រើសរើសចេញពីមន្ត្រីរាជការ។

**មាត្រា១៩ .-**

មន្ត្រីសុខាភិបាលដែលបានបញ្ចប់កម្មសិក្សាដោយជោគជ័យ និងមន្ត្រីសុខាភិបាលដែលមិនតម្រូវឱ្យធ្វើកម្មសិក្សា ត្រូវបានតាំងស៊ប់តាមក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ ដូចខាងក្រោម៖

១- មន្ត្រីសុខាភិបាលឧត្តម ដែលមាន៖
- សញ្ញាបត្រវិជ្ជាជីវៈសុខាភិបាលកម្រិតបណ្ឌិត/ឯកទេសឬសមមូល ត្រូវតាំងស៊ប់ក្នុងឋានន្តរសក្តិមន្ត្រីសុខាភិបាលឧត្តមដើមខ្សែ ថ្នាក់លេខ២(ក.២.២)
- សញ្ញាបត្រវិជ្ជាជីវៈសុខាភិបាលកម្រិតជំនាញឬសមមូល ត្រូវតាំងស៊ប់ក្នុងឋានន្តរសក្តិមន្ត្រីសុខាភិបាលឧត្តមដើមខ្សែ ថ្នាក់លេខ៣(ក.២.៣)
- សញ្ញាបត្រវេជ្ជបណ្ឌិត ត្រូវតាំងស៊ប់ក្នុងឋានន្តរសក្តិមន្ត្រីសុខាភិបាលឧត្តមដើមខ្សែ ថ្នាក់លេខ៤ (ក.២.៤)

- សញ្ញាបត្រវិជ្ជាជីវៈសុខាភិបាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ឬសមមូល ត្រូវតាំងស៊ប់ក្នុងឋានន្តរសក្តិមន្ត្រីសុខាភិបាលឧត្តម ថ្នាក់លេខ២(ក.៣.២)
- សញ្ញាបត្រវិជ្ជាជីវៈសុខាភិបាលកម្រិតបរិញ្ញាបត្រឬសមមូល ត្រូវតាំងស៊ប់ក្នុងឋានន្តរសក្តិមន្ត្រីសុខាភិបាលឧត្តម ថ្នាក់លេខ៣(ក.៣.៣)។

២- មន្ត្រីសុខាភិបាលមធ្យមដែលមានសញ្ញាបត្រវិជ្ជាជីវៈសុខាភិបាលកម្រិតបរិញ្ញាបត្ររងឬសមមូល ត្រូវតាំងស៊ប់ក្នុងឋានន្តរសក្តិមន្ត្រីសុខាភិបាលមធ្យម ថ្នាក់លេខ៣(ខ.៣.៣)។

៣- មន្ត្រីសុខាភិបាលបឋមដែលមានសញ្ញាបត្រវិជ្ជាជីវៈសុខាភិបាលកម្រិតបឋមឬសមមូល ត្រូវតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ថ្នាក់លេខ៩(គ.៩)។

៤- មន្ត្រីសុខាភិបាលដែលជ្រើសរើសចេញពីចំណោមមន្ត្រីរាជការ ត្រូវតាំងស៊ប់ក្នុងឋានន្តរសក្តិសមស្របនៃក្របខ័ណ្ឌដែលបានប្រឡងជាប់ ដោយទទួលបានសន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់នៃសន្ទស្សន៍ចាស់របស់សាមីខ្លួន ព្រមទាំងរក្សាអតីតភាពដែលមានពីមុន។

៥- មន្ត្រីសុខាភិបាលដែលជ្រើសរើសពីក្នុងចំណោមមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ និងមន្ត្រីជាប់កិច្ចសន្យា ត្រូវបញ្ចូលទៅក្នុងឋានន្តរសក្តិនិងថ្នាក់ ផ្អែកលើអតីតភាពការងារក្នុងមុខតំណែងវិជ្ជាជីវៈសុខាភិបាល ដោយយកមូលដ្ឋាន៣(បី)ឆ្នាំ សម្រាប់ផ្តល់ជូន១(មួយ)ថ្នាក់។

**មាត្រា២០ .-**

ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការនៃអង្គសុខាភិបាលគ្រប់កម្រិតនៅថ្នាក់ជាតិ ត្រូវមានការចូលរួមយោបល់ពីគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃកម្មសិក្សា ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នឬតំណាង | ប្រធាន |
| - ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ឬតំណាង | សមាជិក |
| - ប្រធាននាយកដ្ឋានធនធានមនុស្សឬតំណាង | សមាជិក |
| - អ្នករាជការមួយរូបដែលមានក្របខ័ណ្ឌជាមួយគ្នា | សមាជិក។ |

ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃលើកម្មសិក្សា គណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃកម្មសិក្សាក្រសួង ស្ថាប័ន ត្រូវធ្វើកំណត់ហេតុ និងលើកសំណើមករដ្ឋមន្ត្រីក្រសួងសុខាភិបាល ដើម្បីពិនិត្យនិងសម្រេចការតាំងស៊ប់ក្នុងក្របខ័ណ្ឌដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា២១ .-**

ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការនៃអង្គសុខាភិបាលគ្រប់កម្រិតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានការចូលរួមយោបល់ពីគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃកម្មសិក្សា ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - អភិបាលនៃគណៈអភិបាលឬតំណាង | ប្រធាន |
| - ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ឬតំណាង | សមាជិក |
| - ប្រធានអង្គភាពទទួលបន្ទុកធនធានមនុស្សឬតំណាង | សមាជិក |
| - អ្នករាជការមួយរូបដែលមានក្របខ័ណ្ឌជាមួយគ្នា | សមាជិក។ |

ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃលើកម្មសិក្សា គណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃកម្មសិក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើកំណត់ហេតុនិងលើកសំណើមករដ្ឋមន្ត្រីក្រសួងសុខាភិបាល ដើម្បីពិនិត្យនិងសម្រេចការតាំងស៊ប់ក្នុងក្របខ័ណ្ឌដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា២២ .-**

ក្នុងរយៈពេល៣(បី)ខែ យ៉ាងយូរក្រោយផុតកំណត់រយៈពេលកម្មសិក្សា រដ្ឋមន្ត្រីក្រសួងសុខាភិបាល ដោយផ្អែកលើការវាយតម្លៃរបស់គណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃកម្មសិក្សា ត្រូវសម្រេចអំពី៖

- ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ឬ
- ការអនុញ្ញាតឱ្យបន្តកម្មសិក្សា ឬ
- ការបញ្ឈប់មិនឱ្យធ្វើការ។

ក្នុងករណីពុំមានលិខិតបទដ្ឋានគតិយុត្តណាមួយពាក់ព័ន្ធនឹងការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ឬការអនុញ្ញាតឱ្យបន្តកម្មសិក្សា ឬក៏ការបញ្ឈប់មិនឱ្យធ្វើការ បន្ទាប់ពីរយៈពេល៣(បី)ខែ ក្រោយផុតកំណត់រយៈពេលកម្មសិក្សាសាមីខ្លួនមានសិទ្ធិទទួលបាននូវការតាំងស៊ប់ ដោយរាប់គិតចាប់ពីថ្ងៃផុតកំណត់នៃកម្មសិក្សា។

មន្ត្រីសុខាភិបាលដែលពុំទទួលបានជោគជ័យក្នុងការធ្វើកម្មសិក្សាឬពុំទទួលការអនុញ្ញាតឱ្យបន្តកម្មសិក្សា នឹងត្រូវបញ្ឈប់ពីការងារឬត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌចំពោះករណីមន្ត្រីសុខាភិបាលដែលត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការ។

## ផ្នែកទី៣
## ការតែងតាំងនិងការបញ្ចប់មុខតំណែង

**មាត្រា២៣ .-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌរួច មន្ត្រីសុខាភិបាលឧត្តម មន្ត្រីសុខាភិបាលមធ្យម និងមន្ត្រីសុខាភិបាលបឋម អាចទទួលបានការតែងតាំងក្នុងមុខតំណែងទំនេរណាមួយក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមអង្គភាពថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ការតែងតាំងមន្ត្រីសុខាភិបាលក្នុងមុខតំណែងណាមួយក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមអង្គភាពថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្អែកលើគុណវុឌ្ឍិដែលមានកំណត់នៅក្នុងការពិពណ៌នាមុខតំណែង ដោយអនុលោមតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

ការតែងតាំងមុខតំណែងមន្ត្រីសុខាភិបាល ត្រូវសម្រេចដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬដីកា ផ្អែកលើកម្រិតនៃមុខតំណែងនីមួយៗ ដោយអនុលោមតាមបែបបទនិងនីតិវិធីដែលមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២៤ .-**

មន្ត្រីសុខាភិបាល ត្រូវបានបញ្ចប់មុខតំណែង ក្នុងករណីដូចខាងក្រោម៖

- មរណភាព
- ការចូលនិវត្តន៍ឬការដាក់ឱ្យចូលនិវត្តន៍មុនអាយុកំណត់
- ការលាឈប់ពីមុខតំណែង
- ការបាត់បង់សម្បទាវិជ្ជាជីវៈ
- ការដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម
- ការបញ្ឈប់ពីការងារដោយបង្ខំឬការបណ្តេញចេញពីមុខតំណែងមន្ត្រីរាជការ
- ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស
- ការផ្លាស់ប្តូរកន្លែងធ្វើការឬការផ្ទេរអង្គវិជ្ជាជីវៈ
- ការផ្តន្ទាទោសជាបទឧក្រិដ្ឋឬជាបទមជ្ឈិមដោយឥតព្យួរទោស គិតពីសាលក្រមឬសាលដីកាចូលជាស្ថាពរ
- ការលុបនិងការកែសម្រួលរចនាសម្ព័ន្ធនិងមុខតំណែង
- ការសម្រេចផ្សេងទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា២៥ .-**

ការបញ្ចប់មុខតំណែងមន្ត្រីសុខាភិបាល ដែលមានកំណត់ក្នុងមាត្រា២៤ នៃព្រះរាជក្រឹត្យនេះ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬដីកា ផ្អែកលើកម្រិតនៃមុខតំណែងនីមួយៗ និងត្រូវអនុវត្តដោយអនុលោមតាមបែបបទនិងនីតិវិធីដែលមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្នុងករណីមន្ត្រីសុខាភិបាលប្រព្រឹត្តកំហុសធ្ងន់ក្នុងវិជ្ជាជីវៈសុខាភិបាល និងផ្អែកលើស្ថានភាពបន្ទាន់ ឬចាំបាច់ ដើម្បីធានានូវផលប្រយោជន៍សាធារណៈ ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់អាចសម្រេចផ្អាកមុខងារមន្ត្រីសុខាភិបាលនោះ ហើយត្រូវរៀបចំចាត់ចែងបំពេញតាមបែបបទនិងនីតិវិធីបញ្ចប់មុខតំណែង យ៉ាងយូរ ៣០(សាមសិប)ថ្ងៃ ក្រោយការចេញសេចក្តីសម្រេចផ្អាកមុខងារ។

**មាត្រា២៦ .-**

មន្ត្រីសុខាភិបាលដែលត្រូវបានបញ្ចប់មុខតំណែងគ្រប់គ្រងដោយភាពចាំបាច់នៃដំណើរការការងាររបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឬការលុបនិងការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង ត្រូវបានរក្សាទុកនូវក្របខ័ណ្ឌ ឋានន្តរសក្តិ ថ្នាក់ ព្រមទាំងអត្ថប្រយោជន៍នៃមុខតំណែងដើម ដែលអនុញ្ញាតដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន រហូតដល់មានការតែងតាំងក្នុងមុខតំណែងថ្មីសមស្រប លើកលែងមន្ត្រីសុខាភិបាលរូបនោះ ត្រូវបានបញ្ចប់មុខតំណែងដោយមូលហេតុកំហុសធ្ងន់ក្នុងវិជ្ជាជីវៈ ដែលត្រូវអនុវត្តតាមនីតិវិធីដាក់ទណ្ឌកម្មខាងវិន័យ។

**មាត្រា២៧ .-**

មន្ត្រីសុខាភិបាលដែលត្រូវបានបញ្ចប់ឬបាត់បង់មុខតំណែងវិជ្ជាជីវៈឬមុខតំណែងគ្រប់គ្រង ទោះក្នុងមូលហេតុណាក៏ដោយ មិនមានភារកិច្ចឬសិទ្ធិអំណាចក្នុងមុខតំណែងនោះចាប់ពីកាលបរិច្ឆេទនៃការបញ្ចប់ ឬបាត់បង់មុខតំណែង។

សាមីជនមានកាតព្វកិច្ចផ្ទេរនូវទ្រព្យសម្បត្តិរដ្ឋនិងឯកសារផ្លូវការទាំងអស់ដែលបានប្រើប្រាស់ គ្រប់គ្រង និងចាត់ចែងក្នុងពេលបំពេញការងារ មកអង្គភាពសាមីវិញឱ្យបានរួចរាល់យ៉ាងយូរ១(មួយ)សប្តាហ៍ ក្រោយការបញ្ចប់ឬបាត់បង់មុខតំណែង។

**មាត្រា២៨ .-**

មន្ត្រីសុខាភិបាល មិនត្រូវបានទទួលការចាត់តាំង តែងតាំង ឬប្រគល់ភារកិច្ចឱ្យបំពេញមុខតំណែងវិជ្ជាជីវៈ ឬក៏មុខតំណែងគ្រប់គ្រងក្រៅពីរចនាសម្ព័ន្ធគ្រប់គ្រងក្នុងវិស័យសុខាភិបាល លើកលែងតែមានការសម្រេចដោយឡែករបស់រាជរដ្ឋាភិបាល។

## ផ្នែកទី៤
## ការផ្លាស់ប្តូរកន្លែងធ្វើការ

**មាត្រា២៩ .-**

មន្ត្រីសុខាភិបាល ត្រូវបំពេញការងារនៅតាមអង្គភាពដែលសាមីខ្លួនបានជ្រើសរើសនៅពេលប្រឡងប្រជែង។ ការផ្លាស់ប្តូរកន្លែងធ្វើការអាចត្រូវបានអនុញ្ញាតដោយផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

- មុខតំណែងទំនេរ
- គុណវុឌ្ឍិសមស្របរបស់មន្ត្រីសម្រាប់មុខតំណែងទំនេរ
- តម្រូវការចាំបាច់នៃការបំពេញមុខតំណែងទំនេររបស់អង្គភាព

- ការឯកភាពពីប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ដែលមានតម្រូវការមន្ត្រីបន្ថែម
- ការឯកភាពពីប្រធានអង្គភាពគ្រប់គ្រងផ្ទាល់របស់មន្ត្រីសាមី
- បំពេញបែបបទនិងនីតិវិធីជាធរមាន។

បែបបទនិងនីតិវិធីនៃការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីសុខាភិបាលនៅថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ផ្នែកទី៥
## ការផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌក្នុងអង្គសុខាភិបាល

**មាត្រា៣០ .-**

មន្ត្រីសុខាភិបាល ត្រូវបំពេញការងារនៅក្នុងប្រភេទក្របខ័ណ្ឌនៃអង្គសុខាភិបាល ដែលសាមីខ្លួនបានជ្រើសរើសនៅពេលប្រឡងប្រជែង។

ការផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌ ត្រូវបានអនុញ្ញាតដោយផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

- មុខតំណែងទំនេរ
- ការបំពេញគ្រប់គ្រាន់នូវគុណវុឌ្ឍិនៃមុខតំណែងនិងលក្ខខណ្ឌនានាដែលតម្រូវដោយក្របខ័ណ្ឌនៃអង្គសុខាភិបាលដែលត្រូវផ្លាស់ប្តូរចូល
- ការឯកភាពពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល
- ការឯកភាពពីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- ការពិនិត្យនិងសម្រេចពីប្រមុខរាជរដ្ឋាភិបាល។

បែបបទនិងនីតិវិធីនៃការផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌរបស់មន្ត្រីសុខាភិបាល ត្រូវអនុវត្តដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៣១ .-**

មន្ត្រីសុខាភិបាលបឋមដែលស្ថិតក្នុងថ្នាក់ខ្ពស់បំផុត «គ.១» ហើយមិនទាន់ដល់អាយុចូលនិវត្តន៍ ត្រូវអនុញ្ញាតឱ្យប្តូរទៅក្នុងប្រភេទក្របខ័ណ្ឌ ខ ក្នុងឋានន្តរសក្តិនិងថ្នាក់ ដែលមានសន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ញាបត្របរិញ្ញាបត្ររងឬសញ្ញាបត្រសមមូលក្នុងជំនាញវិជ្ជាជីវៈសុខាភិបាល សមស្របតាមតម្រូវការនៃការងារ
- មានអតីតភាពការងារយ៉ាងតិច២(ពីរ)ឆ្នាំ បន្ទាប់ពីការដំឡើងឋានន្តរសក្តិនិងថ្នាក់ចុងក្រោយឬមន្ត្រីរាជការបានបំពេញលក្ខខណ្ឌសម្រាប់ការឡើងថ្នាក់ផ្សេងទៀត ដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ។

មន្ត្រីសុខាភិបាលបឋម ដែលស្ថិតក្នុងថ្នាក់ខ្ពស់បំផុត «គ.១» ហើយមិនទាន់ដល់អាយុចូលនិវត្តន៍ ត្រូវអនុញ្ញាតឱ្យប្តូរទៅក្នុងប្រភេទក្របខ័ណ្ឌ ក ក្នុងឋានន្តរសក្តិនិងថ្នាក់ ដែលមានសន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ញាបត្របរិញ្ញាបត្រឬសញ្ញាបត្រសមមូលក្នុងជំនាញវិជ្ជាជីវៈសុខាភិបាល សមស្របតាមតម្រូវការនៃការងារ
- មានអតីតភាពការងារយ៉ាងតិច២(ពីរ)ឆ្នាំ បន្ទាប់ពីការដំឡើងឋានន្តរសក្តិនិងថ្នាក់ចុងក្រោយឬមន្ត្រីរាជការបានបំពេញលក្ខខណ្ឌសម្រាប់ការឡើងថ្នាក់ផ្សេងទៀត ដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៣២ .-**

មន្ត្រីសុខាភិបាលមធ្យមដែលស្ថិតក្នុងថ្នាក់និងឋានន្តរសក្តិខ្ពស់បំផុត «ខ.១.១» ហើយមិនទាន់ដល់អាយុចូលនិវត្តន៍ ត្រូវអនុញ្ញាតឱ្យប្តូរទៅក្នុងប្រភេទក្របខ័ណ្ឌ ក ក្នុងឋានន្តរសក្តិនិងថ្នាក់ ដែលមានសន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ញាបត្របរិញ្ញាបត្រឬសញ្ញាបត្រសមមូលក្នុងជំនាញវិជ្ជាជីវៈសុខាភិបាល សមស្របតាមតម្រូវការនៃការងារ
- មានអតីតភាពការងារយ៉ាងតិច២(ពីរ)ឆ្នាំ បន្ទាប់ពីការដំឡើងឋានន្តរសក្តិនិងថ្នាក់ចុងក្រោយឬមន្ត្រីរាជការបានបំពេញលក្ខខណ្ឌសម្រាប់ការឡើងថ្នាក់ផ្សេងទៀត ដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ។

**មាត្រា៣៣.-**

មន្ត្រីសុខាភិបាលឧត្តមដែលស្ថិតក្នុងថ្នាក់និងឋានន្តរសក្តិខ្ពស់បំផុត «ក.១.១» ហើយមិនទាន់ដល់អាយុចូលនិវត្តន៍ ត្រូវទទួលបានអត្ថប្រយោជន៍បន្ថែមផ្អែកលើអតីតភាពការងារ ដែលត្រូវកំណត់ដោយរាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៦
## ការផ្ទេរអង្គសុខាភិបាល

**មាត្រា៣៤ .-**

ការផ្ទេរមន្ត្រីរាជការនៃអង្គសុខាភិបាល ទៅអង្គផ្សេងទៀត ត្រូវបានអនុញ្ញាតដោយផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

- មុខតំណែងទំនេរ
- ការបំពេញគ្រប់គ្រាន់នូវគុណវុឌ្ឍិនៃមុខតំណែងនិងលក្ខខណ្ឌនានាដែលតម្រូវដោយអង្គដែលត្រូវផ្ទេរចូល
- ការឯកភាពពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល
- ការឯកភាពពីប្រធានស្ថាប័នទទួលបន្ទុកអង្គ
- ការឯកភាពពីប្រធានស្ថាប័ន ដែលត្រូវផ្ទេរចូល
- ការឯកភាពពីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- ការពិនិត្យនិងសម្រេចពីប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៣៥ .-**

ការផ្ទេរមន្ត្រីរាជការនៃអង្គផ្សេងទៀត មកក្នុងអង្គសុខាភិបាល ត្រូវបានអនុញ្ញាតដោយផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

- មុខតំណែងទំនេរ
- ការបំពេញគ្រប់គ្រាន់នូវគុណវុឌ្ឍិនៃមុខតំណែងនិងលក្ខខណ្ឌនានាដែលតម្រូវដោយអង្គសុខាភិបាល
- មានការទទួលស្គាល់ដោយគណៈវិជ្ជាជីវៈសុខាភិបាលឬក្រសួងសុខាភិបាល
- ការឯកភាពពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល
- ការឯកភាពពីប្រធានស្ថាប័នគ្រប់គ្រងមន្ត្រីសាមី
- ការឯកភាពពីប្រធានស្ថាប័នដែលត្រូវផ្ទេរចេញ
- ការឯកភាពពីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- ការពិនិត្យនិងសម្រេចពីប្រមុខរាជរដ្ឋាភិបាល។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS

**មាត្រា៣៦ .-**

បែបបទនិងនីតិវិធីនៃការផ្ទេរមន្ត្រីរាជការរវាងអង្គសុខាភិបាល និងអង្គផ្សេងទៀត ត្រូវអនុវត្តដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៧
## ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់

**មាត្រា៣៧ .-**

មន្ត្រីសុខាភិបាលដែលមានសិទ្ធិទទួលការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ត្រូវបំពេញព្រឹត្តិបត្រពិន្ទុសម្រាប់ដំឡើងថ្នាក់របស់ខ្លួននៅរៀងរាល់ខែមករា នៃឆ្នាំនីមួយៗ។

ការពិនិត្យនិងការវាយតម្លៃសម្រាប់ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ជូនមន្ត្រីសុខាភិបាល ត្រូវធ្វើឡើងនៅរៀងរាល់ខែមិថុនា នៃឆ្នាំនីមួយៗ។

ការសម្រេចការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ជូនមន្ត្រីសុខាភិបាល ត្រូវធ្វើឡើងនៅថ្ងៃទី១៣ ខែមេសា ក្នុងឆ្នាំបន្ទាប់។

ការរៀបចំបៀវត្សផ្អែកលើឋានន្តរសក្តិនិង/ឬថ្នាក់ថ្មីរបស់មន្ត្រីសុខាភិបាល ត្រូវអនុវត្តចាប់ពីថ្ងៃទី១៥ ខែមេសា តទៅ។

**មាត្រា៣៨ .-**

ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ជូនមន្ត្រីសុខាភិបាលថ្នាក់ជាតិ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាលឬរដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នគ្រប់គ្រងមន្ត្រីសាមី។

**មាត្រា៣៩ .-**

ការពិនិត្យ ការវាយតម្លៃ និងការសម្រេចសម្រាប់ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ជូនមន្ត្រីសុខាភិបាលដែលជាបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តដោយអនុលោមតាមបែបបទនិងនីតិវិធី ដែលមានកំណត់នៅក្នុងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

## អនុផ្នែកទី១
## ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ដោយឆ្លងកាត់ការពិនិត្យនិងការវាយតម្លៃ

**មាត្រា៤០ .-**

ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ប្រចាំឆ្នាំ ផ្អែកលើអតីតភាពការងារសម្រាប់មន្ត្រីសុខាភិបាល ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

ក- មន្ត្រីសុខាភិបាល ត្រូវបានដំឡើងថ្នាក់ប្រចាំឆ្នាំ១(មួយ)ថ្នាក់ ក្នុងករណី៖

- បានបំពេញការងារក្នុងរយៈពេលអប្បបរមា២(ពីរ)ឆ្នាំគិតចាប់ពីថ្ងៃតាំងស៊ប់ឬថ្ងៃឡើងថ្នាក់ចុងក្រោយរហូតដល់ថ្ងៃទី១៣ ខែមេសា នៃឆ្នាំនីមួយៗ។ អតីតភាពការងារមន្ត្រីសុខាភិបាលដែលធ្វើការនៅតំបន់ឆ្ងាយដាច់ស្រយាល តំបន់ប៉ះពាល់សុខភាពឬគ្រោះថ្នាក់ ត្រូវគិតបន្ថែមពាក់កណ្តាលនៃអតីតភាពនេះទៀត ក្នុងការចុះឈ្មោះលើតារាងរាយនាមសម្រាប់ស្នើសុំដំឡើងថ្នាក់
- មិនត្រូវបានទទួលរងទណ្ឌកម្មខាងវិន័យថ្នាក់ទី២ឬទណ្ឌកម្មវិន័យថ្នាក់ទី១ រួមមាន ការស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន ការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ ការលុបឈ្មោះចេញពីតារាងឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ក្នុងរយៈពេលនៃអតីតភាពការងារ២(ពីរ)ឆ្នាំ។

ខ- មន្ត្រីសុខាភិបាលដែលមិនត្រូវបានដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ដែលមានកំណត់ក្នុងចំណុច ក នៃមាត្រា៤០ នៃព្រះរាជក្រឹត្យនេះ នឹងត្រូវបានដំឡើងថ្នាក់ប្រចាំឆ្នាំ១(មួយ)ថ្នាក់ ក្នុងឆ្នាំទី៣ នៃអតីតភាពការងាររបស់ខ្លួន លើកលែងតែមន្ត្រីរាជការនោះ ត្រូវបានទទួលទណ្ឌកម្មខាងវិន័យថ្នាក់ទី២។

គ- ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ប្រចាំឆ្នាំ ធ្វើបានម្តងតែមួយថ្នាក់ប៉ុណ្ណោះ។

**មាត្រា៤១ .-**

មន្ត្រីសុខាភិបាល ដែលបានបំពេញការងារមានស្នាដៃល្អពិសេសក្នុងមុខតំណែង ដើម្បីគាំទ្រដល់វិស័យសុខាភិបាល ត្រូវបានដំឡើងថ្នាក់១(មួយ)ថ្នាក់ ដោយពុំគិតពីលក្ខខណ្ឌអតីតភាពឡើយ។ ប្រធានអង្គភាពគ្រប់គ្រងមន្ត្រីសាមី ត្រូវលើកសំណើបេក្ខភាពមន្ត្រីដែលមានស្នាដៃល្អពិសេស ជូនគណៈកម្មការចំណាត់ថ្នាក់របស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិសាមី។

**មាត្រា៤២ .-**

ការពិនិត្យនិងការវាយតម្លៃសម្រាប់ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ជូនមន្ត្រីសុខាភិបាលថ្នាក់ជាតិដូចមានចែងក្នុងមាត្រា៤០ និងមាត្រា៤១ នៃព្រះរាជក្រឹត្យនេះ ត្រូវធ្វើឡើងដោយគណៈកម្មការចំណាត់ថ្នាក់របស់ក្រសួង ស្ថាប័នសាមី ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នឬតំណាង | ប្រធាន |
| - អគ្គលេខាធិការ ឬអគ្គនាយក ឬក៏មុខតំណែងប្រហាក់ប្រហែល | អនុប្រធាន |
| - អគ្គលេខាធិការរង ឬអគ្គនាយករង ឬក៏មុខតំណែងប្រហាក់ប្រហែល១(មួយ)រូប | សមាជិក |
| - ប្រធាននាយកដ្ឋានធនធានមនុស្ស | សមាជិក |
| - តំណាងក្របខ័ណ្ឌនីមួយៗ១(មួយ)រូប | សមាជិក។ |

គណៈកម្មការនេះមានភារកិច្ចពិនិត្យនិងវាយតម្លៃសម្រាប់ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ចំពោះមន្ត្រីសុខាភិបាលថ្នាក់ជាតិ និងត្រូវរៀបចំសំណើសម្រាប់ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់របស់មន្ត្រីរាជការជូនប្រធានស្ថាប័នដើម្បីពិនិត្យនិងសម្រេច។

## អនុផ្នែកទី២
## ការដំឡើងឋានន្តរសក្តិនិង/ឬថ្នាក់ ដោយមិនឆ្លងកាត់ការវាយតម្លៃ

**មាត្រា៤៣ .-**

មន្ត្រីសុខាភិបាល ត្រូវបានដំឡើងថ្នាក់១(មួយ)ថ្នាក់ ដោយមិនឆ្លងកាត់ការវាយតម្លៃពីគណៈកម្មការចំណាត់ថ្នាក់ ក្នុងករណីដូចខាងក្រោម៖

- បានទទួលការបណ្តុះបណ្តាលដោយជោគជ័យក្នុងវគ្គសុក្រឹតការឬវិក្រឹតការណាមួយ ដែលមានរយៈពេលយ៉ាងតិច៩(ប្រាំបួន)ខែ ឡើងទៅ នៅគ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈ
- បានទទួលការបណ្តុះបណ្តាលជំនាញសមស្របតាមការតម្រូវនៃអង្គសុខាភិបាល ដែលមានរយៈពេលយ៉ាងតិច៩(ប្រាំបួន)ខែ ដោយមានសញ្ញាបត្រឬវិញ្ញាបនបត្របញ្ជាក់ទទួលស្គាល់ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច
- ត្រូវបានផ្លាស់ប្តូរកន្លែងការងារតាមគោលការណ៍ពង្រាយមន្ត្រីរាជការដែលកំណត់ដោយរាជរដ្ឋាភិបាល
- មានអតីតភាពការងារយ៉ាងតិច២(ពីរ)ឆ្នាំ សម្រាប់មន្ត្រីរាជការដែលត្រូវបានអនុញ្ញាត៖
  - ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬ
  - ឱ្យទៅបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេសឬនៅតាមអង្គការអន្តរជាតិ។

មន្ត្រីសុខាភិបាលដែលទទួលបានការដំឡើងថ្នាក់តាមការបណ្តុះបណ្តាលឬតាមគោលការណ៍ពង្រាយមន្ត្រីរាជការ មានសិទ្ធិទទួលបានការដំឡើងថ្នាក់ប្រចាំឆ្នាំផ្អែកលើវេនជ្រើសរើសឬអតីតភាពដូចមានចែងក្នុងមាត្រា៤០ នៃព្រះរាជក្រឹត្យនេះ។

**មាត្រា៤៤ .-**

ឋានន្តរសក្តិកិត្តិយស អាចត្រូវផ្តល់ជូនមន្ត្រីសុខាភិបាលដែលចូលនិវត្តន៍ ឬលាលែង ឬក៏ដែលបានដាក់ឱ្យឈប់ធ្វើការងារដោយបាត់បង់សមត្ថភាពការងារ។

ឋានន្តរសក្តិកិត្តិយសជាកិច្ចបច្ឆាមរណៈ អាចផ្តល់ជូនមន្ត្រីរាជការដែលបានទទួលមរណភាព។

ឋានន្តរសក្តិទាំងពីរប្រភេទនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាលឬរដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នគ្រប់គ្រងមន្ត្រីសាមី ឬក៏ដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ឋានន្តរសក្តិកិត្តិយសឬឋានន្តរសក្តិកិត្តិយសជាកិច្ចបច្ឆាមរណៈ មិនត្រូវទទួលបានអត្ថប្រយោជន៍ហិរញ្ញវត្ថុឡើយ។

## ផ្នែកទី៨
## ស្ថានភាពបំពេញការងារនិងស្ថានភាពរដ្ឋបាល

**មាត្រា៤៥ .-**

ការដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ការកំណត់ពេលវេលាបំពេញការងារ ការឈប់សម្រាកពីការងារ និងការអនុវត្តទណ្ឌកម្មខាងវិន័យ ព្រមទាំងការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីសុខាភិបាល ត្រូវអនុវត្តដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៩
## ការអភិវឌ្ឍសមត្ថភាព

**មាត្រា៤៦ .-**

មន្ត្រីសុខាភិបាលក្នុងមុខតំណែងវិជ្ជាជីវៈនិងមុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃអង្គសុខាភិបាល ត្រូវចូលរួមវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា ឬក៏វគ្គសិក្សាពាក់ព័ន្ធនឹងមុខតំណែងរបស់ខ្លួនដើម្បីធ្វើបច្ចុប្បន្នកម្មចំណេះដឹង បង្កើនសមត្ថភាពវិជ្ជាជីវៈ និងសមត្ថភាពគ្រប់គ្រង ផ្អែកតាមតម្រូវការនៃមុខតំណែងនីមួយៗ។

រយៈពេលនិងចំនួនក្រេឌីតសម្រាប់ការអភិវឌ្ឍសមត្ថភាពមុខតំណែងវិជ្ជាជីវៈនិងមុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃអង្គសុខាភិបាល ត្រូវកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធនីមួយៗឬតាមការកំណត់របស់ក្រសួងសុខាភិបាល។

## ផ្នែកទី១០
## វិន័យនិងសីលធម៌

**មាត្រា៤៧ .-**

មន្ត្រីសុខាភិបាល ត្រូវគោរពនិងអនុវត្តនូវបទប្បញ្ញត្តិដែលពាក់ព័ន្ធដូចខាងក្រោម៖

- សិទ្ធិនិងកាតព្វកិច្ចដែលមានកំណត់ដោយច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- គុណសម្បត្តិនៃឥរិយាបថរបស់មន្ត្រីរាជការ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- ក្រមសីលធម៌ឬក្រមប្រតិបត្តិមន្ត្រីរាជការស៊ីវិល
- ក្រមសីលធម៌វិជ្ជាជីវៈសុខាភិបាល
- វិន័យនិងបទបញ្ញាផ្ទៃក្នុងដែលកំណត់ដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាព ដែលគ្រប់គ្រងមន្ត្រីរាជការ។

## ផ្នែកទី១១
## ការចូលនិវត្តន៍និងការបាត់បង់សម្បទាវិជ្ជាជីវៈ

### មាត្រា៤៨ .-

មន្ត្រីសុខាភិបាលគ្រប់ប្រភេទក្របខ័ណ្ឌ ត្រូវដាក់ឱ្យចូលនិវត្តន៍នៅពេលដល់អាយុ៦០(ហុកសិប)ឆ្នាំ នៅថ្ងៃទី១ នៃខែបន្ទាប់ ឬត្រូវដាក់ឱ្យចូលនិវត្តន៍មុនកាលកំណត់ ឬកំណត់ថាបាត់បង់សម្បទាវិជ្ជាជីវៈ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មន្ត្រីសុខាភិបាលគ្រប់ប្រភេទក្របខ័ណ្ឌដែលចូលនិវត្តន៍តាមកាលកំណត់ឬចូលនិវត្តន៍មុនកាលកំណត់ ឬបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវទទួលបានអត្ថប្រយោជន៍ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### មាត្រា៤៩ .-

ក្នុងត្រីមាសទី១ នៃឆ្នាំនីមួយៗ ក្រសួងមុខងារសាធារណៈ ត្រូវជូនដំណឹងដល់គ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីស្ថានភាពមន្ត្រីសុខាភិបាល ដែលត្រូវចូលនិវត្តន៍នៅឆ្នាំបន្ទាប់។ ក្រសួងមុខងារសាធារណៈ ត្រូវរៀបចំការដាក់មន្ត្រីសុខាភិបាលឱ្យចូលនិវត្តន៍ឱ្យបានមុន៦(ប្រាំមួយ)ខែ មុនកាលបរិច្ឆេទនៃការចូលនិវត្តន៍របស់មន្ត្រីសាមី ដោយបំពេញបែបបទនិងនីតិវិធីផ្អែកលើកម្រិតមុខតំណែងដូចខាងក្រោម៖

- មន្ត្រីសុខាភិបាលដែលកំពុងបំពេញមុខតំណែងគ្រប់គ្រង ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ត្រូវដាក់ឱ្យចូលនិវត្តន៍និងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ
- មន្ត្រីសុខាភិបាលដែលកំពុងបំពេញមុខតំណែងគ្រប់គ្រង ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ ត្រូវដាក់ឱ្យចូលនិវត្តន៍និងបញ្ចប់មុខតំណែងដោយអនុក្រឹត្យ
- មន្ត្រីសុខាភិបាលដែលកំពុងបំពេញមុខតំណែងគ្រប់គ្រង ដែលត្រូវបានតែងតាំងដោយប្រកាស ត្រូវដាក់ឱ្យចូលនិវត្តន៍និងបញ្ចប់មុខតំណែងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- មន្ត្រីសុខាភិបាលដែលកំពុងបំពេញមុខតំណែងគ្រប់គ្រង ដែលត្រូវបានតែងតាំងដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវដាក់ឱ្យចូលនិវត្តន៍និងបញ្ចប់មុខតំណែងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- មន្ត្រីសុខាភិបាលដែលកំពុងបំពេញមុខតំណែងវិជ្ជាជីវៈគ្រប់ប្រភេទ ត្រូវដាក់ឱ្យចូលនិវត្តន៍និងបញ្ចប់មុខតំណែងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

មន្ត្រីសុខាភិបាល ត្រូវបានដាក់ឱ្យចូលនិវត្តន៍មុនកាលកំណត់និងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬដីកា ផ្អែកលើកម្រិតនៃមុខតំណែងនីមួយៗ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មន្ត្រីសុខាភិបាល ត្រូវបានកំណត់ថាបាត់បង់សម្បទាវិជ្ជាជីវៈនិងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬដីកា ផ្អែកលើកម្រិតនៃមុខតំណែងនីមួយៗ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៦
## មន្ត្រីសុខាភិបាលក្រៅក្របខ័ណ្ឌមន្ត្រីរាជការ

**មាត្រា៥០ .-**

មន្ត្រីសុខាភិបាលក្រៅក្របខ័ណ្ឌមន្ត្រីរាជការ សំដៅដល់មន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ មន្ត្រីជាប់កិច្ចសន្យា ឬមន្ត្រីផ្សេងទៀតដែលត្រូវបានជ្រើសរើសដើម្បីបំពេញមុខងារសិក្សាស្រាវជ្រាវ ផ្តល់យោបល់ រៀបចំផែនការ គោលនយោបាយ និងប្រតិបត្តិលើផ្នែកវេជ្ជសាស្ត្រ សុខភាពសាធារណៈ ឱសថសាស្ត្រ ទន្តវេទនសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ នៅតាមគ្រឹះស្ថាន និងអង្គភាពនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

មន្ត្រីសុខាភិបាលក្រៅក្របខ័ណ្ឌមន្ត្រីរាជការ ត្រូវមានគុណវុឌ្ឍិពេញលេញសម្រាប់មុខតំណែងដូចមន្ត្រីសុខាភិបាលក្នុងក្របខ័ណ្ឌមន្ត្រីរាជការ។

ការជ្រើសរើសនិងការគ្រប់គ្រង មន្ត្រីសុខាភិបាលក្រៅក្របខ័ណ្ឌមន្ត្រីរាជការ ត្រូវស្ថិតក្រោមបទប្បញ្ញត្តិទូទៅដែលអនុវត្តចំពោះមន្ត្រីសុខាភិបាល ដែលមានកំណត់ក្នុងព្រះរាជក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៧
## សមាហរណកម្មក្នុងក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់

**មាត្រា៥១ .-**

មន្ត្រីរាជការនៃអង្គសុខាភិបាល ដែលស្ថិតនៅក្រោមព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៤ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៥ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ត្រូវធ្វើសមាហរណកម្មទៅតាមក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ ផ្អែកលើគោលការណ៍ដូចខាងក្រោម៖

- មន្ត្រីរាជការកំពុងបំពេញការងារផ្នែកសិក្សាស្រាវជ្រាវ ផ្តល់យោបល់ រៀបចំផែនការ គោលនយោបាយ និងប្រតិបត្តិលើផ្នែកវេជ្ជសាស្ត្រ សុខភាពសាធារណៈ ឱសថសាស្ត្រ ទន្តវេទនសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រនៅតាមគ្រឹះស្ថាន និងអង្គភាពនៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និង
- មានគុណវុឌ្ឍិនិងបំពេញលក្ខខណ្ឌគ្រប់គ្រាន់ដែលតម្រូវតាមប្រភេទក្របខ័ណ្ឌនៃអង្គសុខាភិបាល ដែលកំណត់ដោយព្រះរាជក្រឹត្យនេះ។

ការធ្វើសមាហរណកម្មនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល បន្ទាប់ពីទទួលបានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសុខាភិបាល ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំនិងលើកផែនការដើម្បីធ្វើសមាហរណកម្មមន្ត្រីរាជការបច្ចុប្បន្ននៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម និងក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ទៅក្នុងក្របខ័ណ្ឌនៃអង្គសុខាភិបាលនៃព្រះរាជក្រឹត្យនេះ ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា៥២ .-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៤ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៥ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៥៣ .-**

ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៧ តទៅ។

ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៤ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៥ ចុះ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៤ .-**

សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ សៅរ៍ ១៤កើត ខែ ជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០២៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

នស. ២៦០៥. ៦៣

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

បណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី**